ស្មារតីឆេះឆួលក្នុងការធ្វើសង្គ្រាម ខ្ញុំជាយុវជនម្នាក់ដែលបានទទួលការហ្វឹកហ្វឺននៅបន្ទាយមួយឈ្មោះថា" ផ្លេតស្បឺក" បន្ទាប់មកគេបានបញ្ជូនខ្ញុំឲ្យទៅសំរាកនៅទីក្រុងក្នុងតំបន់មួយឈ្មោះញ៉ូអ៊ីងគ្លេន នៅសហរដ្ឋអាមេរិក ដើម្បីរង់ចាំចេញទៅធ្វើសង្គ្រាម។ នៅទីក្រុងនេះប្រជាជនគេបានស្វាគមន៍យើងយ៉ាងកក់ក្តៅ ពួកគេឲ្យយើងស្នាក់នៅផ្ទះរបស់គេ មិនតែប៉ុណ្ណោះពួកគេក៏បានរៀបចំពិធីជប់លៀងអបអរសាទរពួកយើង ហើយចាត់ទុកពួកយើងដូចជាវីរជនអ៊ីចឹង។ ខណៈនោះវាធ្វើឲ្យអារម្មណ៍ខ្ញុំសប្បាយខ្លាំងមែនទែនក្នុងកម្មវិធីជប់លៀងស៊ីផឹក។

បន្ទាប់មកពួកយើងបានធ្វើដំណើរតាមនាវាទៅធ្វើសង្គ្រាមនៅប្រទេសផ្សេងទៀត។ ពេលនៅលើនាវានោះ ខ្ញុំហាក់ដូចជាអផ្សុកយ៉ាងខ្លាំង អត់មានអ្វីធ្វើទាល់តែសោះ មានតែផឹកស្រាដើម្បីកំដរអារម្មណ៍ ទាំងភ្លេចពីពាក្យទូន្មាន ប្រៀនប្រដៅរបស់គ្រួសារ និងបំរាមនៅលើនាវាក្នុងការផឹកស្រានេះ។

ពេលនាវាដល់ប្រទេសអង់គ្លេស ខ្ញុំបានទៅលេងព្រះវិហារដ៏ធំមួយឈ្មោះ"វិនឆេស្ទើរ"។ ខ្ញុំដូចជាមានអារម្មណ៍អផ្សុកបន្តិច ដូច្នេះខ្ញុំក៏ចេញទៅដើរលេងជុំវិញព្រះវិហារ ហើយបានប្រទះឃើញកន្លែងបញ្ចុះសពមួយ។ វាគួរឲ្យចាប់អារម្មណ៍មែនទែន នៅលើផ្នូរមានសិលាចារិកមួយផ្ទាំងសរសេរថា៖

"ទាហានកម្មង់ដូរពិសេសម្នាក់បានស្លាប់ដោយសារផឹកស្រាបៀរត្រជាក់ស្រួលខ្លាសេ។ យើងមិនត្រូវភ្លេចទាហានល្អម្នាក់នោះទេ មិនថាគាត់ស្លាប់ដោយសារផឹកស្រាឬគ្រាប់កាំភ្លើងនោះឡើយ"

នេះវាដូចជាការដាស់តឿនមួយយ៉ាងសំខាន់ តែខ្ញុំបែរជាមិនអើពើ។

កាលនៅវ័យ២២ឆ្នាំ ខ្ញុំមានសិទ្ធិពិសេស ជានាយទាហានម្នាក់បានទៅធ្វើសង្គ្រាមនៅក្រៅប្រទេស ហើយបានវិលត្រលប់មកវិញបន្ទាប់ពីបញ្ចប់បេសកកម្ម។ ខ្ញុំបានរាប់ខ្លួនឯងថា ជាអ្នកដឹកនាំម្នាក់ដែលគេគោរព និងមានទេពកោសល្យផ្នែកដឹកនាំ។ ខ្ញុំមានក្តីស្រមៃថា ចង់ក្លាយជានាយកប្រតិបត្តិនៃក្រុមហ៊ុនមួយដែលចាត់ចែងការងារបានប្រកបដោយសក្តានុពល។ អ៊ីចឹងខ្ញុំបានទៅរៀនវគ្គសិក្សា ផ្នែកច្បាប់ នៅពេលយប់ ហើយក៏បានទទួលការងារមួយ ដែលមានតួនាទីជាអ្នកស៊ើបអង្កេតក្នុងក្រុមហ៊ុនផ្តល់ប្រាក់ឥណទាន។ ពេលនោះវាកាន់តែជំរុញទឹកចិត្តរបស់ខ្ញុំឲ្យចង់ក្លាយជាអ្នកជោគជ័យម្នាក់ភ្លាមៗ និងចង់ប្រាប់ពិភពលោកថា ខ្ញុំជាមនុស្សសំខាន់ម្នាក់ដែរ។ តាមរយៈការងារនោះ ខ្ញុំបានទៅកាន់ក្រុមហ៊ុនលក់ភាគហ៊ុនមួយនៅតំបន់ហ្វលស្ទ្រីត។ មិនយូរប៉ុន្មានខ្ញុំក៏ចាប់អារម្មណ៍នឹងការលេងភាគហ៊ុន។ មានអ្នកខ្លះបានលេងចាញ់ខាតលុយជាច្រើន ហើយក៏មានអ្នកខ្លះបានក្លាយជាអ្នកមានមួយរំពេចផងដែរ។ ចុះហេតុអ្វីខ្ញុំមិនអាចក្លាយជាអ្នកមានដូចគេបាន?

ខ្ញុំបានចំណាយពេលសិក្សាផ្នែកសេដ្ឋកិច្ច ពាណិជ្ជកម្ម និងផ្នែកច្បាប់ផងដែរ។ ខ្ញុំស្ទើតែប្រឡងធ្លាក់ផ្នែកច្បាប់ដោយសារតែមានជាតិស្រវឹងក្នុងខ្លួន ហើយវាធ្វើអោយខ្ញុំរកគិតសរសេរអ្វីលែងចេញ នៅពេលប្រឡងផ្តាច់ព្រ័ត។ ទោះបីជាទំលាប់ផឹកស្រាមិនទាន់ធ្ងន់ធ្ងរយ៉ាងណាក៏ដោយ តែវាបានជះឥទ្ធិពលដល់ប្រពន្ធខ្ញុំ ធ្វើឲ្យគាត់មិនស្រួលអារម្មណ៍ទាល់តែសោះ។ យើងបានជជែកគ្នាយ៉ាងយូរ ហើយខ្ញុំបានប្រាប់គាត់ថាៈ"មនុស្សដែលឆ្លាតគេអាចបញ្ចេញគំនិតដ៏អស្ចារ្យរបស់គេបាននៅពេលណាគេផឹក"។

ទស្សនវិទូ អាចបញ្ចេញទ្រឹស្តីនិងគំនិតល្អៗបាននៅពេលណាគេស្រវឹង។

នៅពេលដែលខ្ញុំបានបញ្ចប់វគ្គសិក្សានោះ ខ្ញុំបានដឹងថា ខ្ញុំអត់ចេះច្បាប់ទាល់តែសោះ។

សកម្មភាពទីផ្សារភាគហ៊ុននៅតំបន់វ៉លស្ទ្រីត ធ្វើឲ្យខ្ញុំស្រេកឃ្លានក្នុងការទិញជួរភាគហ៊ុន។ ហើយខ្ញុំចាត់ទុក អ្នកជំនួញនិងហិរញ្ញវត្ថុ ដូចជាវិរជនរបស់ខ្ញុំអ៊ីចឹង។ គំនិត និងមហិច្ឆិតាទាំងនេះ ប្រៀបដូចជាកាំបិតមុខពីរដែលអាចសម្លាប់ខ្ញុំនៅថ្ងៃណាមួយ។ ខ្ញុំនិងប្រពន្ធខ្ញុំសន្សំលុយបាន១០០០ដុល្លា។ ហើយបានសំរេចចិត្តទិញមូលប័ត្រភាគហ៊ុនមួយដែលមានតំលៃថោកមិនសូវមានអ្នកចង់ទិញ តែខ្ញុំគិតថា វានឹងលក់បានវិញក្នុងតំលៃខ្ពស់នៅថ្ងៃណាមួយជាមិនខាន។ ខណៈនោះដែរ ខ្ញុំបានរកមិត្តភក្តិខ្លះដើម្បីជួយឧបត្ថម្ភគាំទ្រខ្ញុំក្នុងការសិក្សាទីផ្សារពោងចក្រនិងក្រុមហ៊ុនផ្សេងៗ ប៉ុន្តែពួកគេមិនបានគាំទ្រខ្ញុំឡើយ។ ខ្ញុំនិងប្រពន្ធខ្ញុំមានម៉ូតូកង់បីមួយ យើងក៏ប្រើប្រាស់វាដើម្បីដឹកឥវ៉ាន់ របស់របរប្រើប្រាស់ខ្លះៗ ខោអាវបីបួនកំប្លេ និងសៀវភៅទីផ្សារភាគហ៊ុនជាច្រើនក្បាលទៅជាមួយ ដើម្បីស្រាវជ្រាវទីផ្សារភាគហ៊ុន។ ហើយមិត្តភក្តិខ្ញុំបានគិតថា ខ្ញុំនឹងប្រពន្ធខ្ញុំធ្វើអ៊ីចឹង វាពិតជាឆ្កួតមែនទែនហើយ។ ប្រហែលជាពួកគេនិយាយត្រូវ។ ខ្ញុំបានលក់មូលប័ត្រភាគហ៊ុនរបស់ខ្ញុំ ក្នុងតម្លៃទាបមួយ អ៊ីចឹងខ្ញុំក៏សំរេចចិត្តទៅរស់នៅ និងធ្វើការនៅជនបទ១ខែ ដើម្បីជៀសវាងការចំណាយច្រើន។ នេះជារយៈពេលមួយយូរសំរាប់ខ្ញុំដែលធ្វើការប្រើកំលាំងបែបហ្នឹង។ បន្ទាប់មកខ្ញុំបានទៅធ្វើការនៅសហរដ្ឋអាមេរិកភាគខាងកើតរយៈពេល១ឆ្នាំ ហើយក៏បានបញ្ចប់ការស្រាវជ្រាវរបស់ខ្ញុំ។ រាល់ទិន្នន័យដែលខ្ញុំរកបាន ខ្ញុំបានផ្ញើឲ្យទៅក្រុមហ៊ុននៅតំបន់វ៉លស្ទ្រីត។ បន្ទាប់មកក្រុមហ៊ុនបានហៅខ្ញុំឲ្យធ្វើការជាមួយ ទាំងអោយតំណែងខ្ពស់ទៀតផង។ គេឲ្យខ្ញុំកាន់ផ្នែកទំនាក់ទំនងទីផ្សារ គេផ្តល់ប្រាក់បៀវត្សខ្ពស់ និងប្រាក់ចាយវាយក្នុងការងារក៏ច្រើនសន្ធឹកផងដែរ។ វាពិតជាធ្វើអោយខ្ញុំហ៊ឺហាមែនទែន។

រយៈពេលពីរ បីឆ្នាំក្រោយមកទៀត យីអ៊ុនរបស់ខ្ញុំកាន់តែឡើងខ្ពស់ លុយហូរចូលដូចទឹក ហើយមានប្រជាប្រិយទៀត។ ខ្ញុំបានទទួលជោគជ័យយ៉ាងខ្លាំង។ តាមការវិនិច្ឆ័យ និងទស្សនៈនៃភាពជោគជ័យរបស់ខ្ញុំនេះ មានមនុស្សច្រើនចង់ដឹង និងរៀនសូត្រតាម ព្រោះថាវាមើលទៅ ឃើញលុយហូរចូលស្រស់ៗតែម្តង។

នៅចុងសតវត្សទី២០ ទីផ្សារភាគហ៊ុនបានផ្ទុះឡើងខ្ពស់ មានអ្នកលក់ អ្នកទិញភាគហ៊ុនកាន់តែច្រើនឡើង ហើយស្របពេលជាមួយគ្នានោះ ខ្ញុំកាន់តែមានអារម្មណ៍សប្បាយក្នុងការស៊ីផឹកផងដែរ។ វាគួរឲ្យរំភើបរីករាយណាស់ ក្នុងការដែលអង្គុយស៊ីផឹកនៅកន្លែងមានតន្ត្រីកំដរ និងប្រជុំជើងសុទ្ធតែអ្នកលេងភាគហ៊ុនជជែកគ្នាពីទីផ្សារភាគហ៊ុន។ ខ្ញុំចាយលុយដូចចាយក្រដាស ថ្ងៃនេះអស់តែមួយពាន់ ពីរពាន់ប៉ុណ្ណោះ ប៉ុន្តែថ្ងៃបន្តបន្ទាប់ទៀត ប្រហែលជាចាយអស់រាប់ម៉ឺនរាប់សែនរាប់លានក៏ថាបាន។ តែវាគួឲ្យអាសូរខ្លួនឯងណាស់ ខ្ញុំមានមិត្តភ័ក្តតែនៅកន្លែងស៊ីផឹកប៉ុណ្ណោះ មិត្តពិតប្រាកដ មិត្តស្លាប់រស់ មិត្តចិត្តមួយថ្លើមមួយគ្មានសូម្បីតែម្នាក់។

ពីមួយថ្ងៃទៅមួយថ្ងៃ ខ្ញុំផឹកកាន់តែច្រើនឡើងៗគ្មានលោះពេល ហើយវាក៏ធ្វើឲ្យខ្ញុំមានទំនាស់ជាមួយមិត្តភក្តិជាច្រើន មិនតែប៉ុណ្ណោះខ្ញុំបានឈ្លោះប្រកែកជាមួយប្រពន្ធខ្ញុំថែមទៀត។ ដោយសារតែភាពស្រវឹងជោគជាំនេះ វាក៏បណ្តាលឲ្យខ្ញុំលែងមានអារម្មណ៍ខាងផ្លូវភេទទៀតដែរ។

នៅឆ្នាំ១៩២៩ ខ្ញុំជក់ចិត្តនឹងការលេងកូនហ្គោល។ ថ្ងៃមួយខ្ញុំបានលេងជាមួយអ្នកល្បីម្នាក់ឈ្មោះលោកវ៉លធើហេហ្គិន។ នៅថ្ងៃនោះខ្ញុំលេងប៉ិះៗឈ្នះគាត់ទៅហើយ។ តែដល់ថ្ងៃបន្ទាប់ខ្ញុំលេងចាញ់គាត់ទាំងស្រុង ដោយសារតែជាតិស្រានៅក្នុងខ្លួន ធ្វើឲ្យខ្ញុំញ័រដៃ ញ័រជើងលេងមិនកើត។ ជាធម្មតានៅពេលលេង គេនិយមដាក់មួយតយពីរតយបណ្តើរលេងបណ្តើរ តែនៅថ្ងៃនោះ ខ្ញុំដាក់រហូតដល់យប់ជ្រៅស្រវឹងជោគជាំ។ វាជារឿងមិនគួរអោយជឿដែលថា ខ្ញុំអាចចូលមកលេងវាយគោលនៅទីនេះបានអ៊ីចឹងសោះ កាលពីក្មេងខ្ញុំគ្រាន់តែមើលគេលេងពីខាងក្រៅប៉ុណ្ណោះ។ មួយទៀតពេលលេង វាធ្វើឲ្យខ្ញុំមានសម្បុរខ្មៅតឡូយមែនទែន ពេលគេឃើញខ្ញុំ គេដឹងថាខ្ញុំជាអ្នកមាន។ បើខ្ញុំទៅធនាគារវិញ បុគ្គលិក និងនាយកនៅទីនោះភ្ញាក់ផ្អើល រំភើប ដោយឃើញខ្ញុំយកលុយ យកសែកទៅដាក់នៅធនាគាច្រើនរាប់ម៉ឺនរាប់សែនបែបនោះ។

នៅខែតុលា ឆ្នាំ១៩២៩ ទីផ្សារភាគហ៊ុននៅក្រុងញ៉ូវយ៉កបានធ្លាក់ចុះយ៉ាងខ្លាំង។ ល្ងាចថ្ងៃនោះ ខ្ញុំបានដើរពីបារ ទៅកាន់ការិយាល័យដេញភាគហ៊ុនទាំងស្រវឹងជីងជោង។ ពេលនោះ ម៉ោងប្រហែលជា៨ ហើយការិយាល័យទីផ្សារភាគហ៊ុនបានបិទទ្វារតាំងពី៥ម៉ោងមុនម្លេះ។ ប៉ុន្តែម៉ាស៊ីនប្រាប់ពត៌មានទីផ្សារភាគហ៊ុននៅដំណើរការរហូត។ នៅទីនោះខ្ញុំបានមើលក្រដាសពត៌មាន ចេញពីម៉ាស៊ីនប្រាប់ថា តំលៃភាគហ៊ុនបានធ្លាក់ចុះរហូតដល់(-៣២)។ កាលពីព្រឹកមិញវាមានពិន្ទុ៥២សោះ តែឥឡូវ វាធ្លាក់ចុះខ្លាំងមែនទែន។ វាធ្វើឲ្យខ្ញុំ មិត្តភក្តិខ្ញុំ និងអ្នកលេងផ្សេងទៀតចាញ់អស់លុយរលីងពីខ្លួន។ ហើយក៏មានពត៌មានទៀតថា មានអ្នកខ្លះចាញ់វាល់លានរហូតដល់ថ្នាក់លោតសំលាប់ខ្លួនពីលើអាគាខ្ពស់ៗផង។ ទង្វើបែបនេះ វាជា

ទង្វើផ្តួតសុទ្ធសំរាប់ខ្ញុំ។ ខ្ញុំមិនទៅភ្លើលោតសំលាប់ខ្លួនអ៊ីចឹងនោះទេ ទុកពេលផឹកស្រាវិញប្រសើរជាង។ ពេលផឹកស្រាស្រវឹង ខ្ញុំនៅតែមានទំនុកចិត្តថា ខ្ញុំមិនចាញ់ទេ ចាំមើលថ្ងៃស្អែក ទីផ្សារភាគហ៊ុនវាយ៉ាងម៉េចដែរ។

លុះព្រឹកឡើង ខ្ញុំបានទូរស័ព្ទទៅមិត្តភក្តិខ្ញុំម្នាក់នៅកាណាដា។ គាត់ជាអ្នកមានម្នាក់។ ខ្ញុំចង់ទៅធ្វើការជាមួយគាត់នៅទីនោះ។ រយៈពេលបីបួនខែក្រោយមក បន្ទាប់ពីបានការងារធ្វើជាមួយមិត្តភក្តិ ខ្ញុំមានជីវភាពប្រសើរឡើងវិញដូចមុន វាធ្វើឲ្យខ្ញុំមានអារម្មណ៍ដូចជាមេទ័ពល្បីម្នាក់បានវិលត្រឡប់មកពីឈ្នះសង្គ្រាមវិញអ៊ីចឹង។

ប៉ុន្តែខ្ញុំនៅតែបន្តផឹករហូត ដល់ថ្នាក់មិត្តភក្តិខ្ញុំលែងឲ្យខ្ញុំធ្វើការ ហើយខ្ញុំក៏អស់លុយរលីងពីខ្លួនផងដែរ។ បន្ទាប់មកយើងបានទៅរស់នៅជាមួយនឹងឪពុកម្តាយខាងប្រពន្ធរបស់ខ្ញុំ។ ខ្ញុំរកការងារបានធ្វើមួយ ហើយក៏ត្រូវបាត់ទៅវិញ ដោយសារតែខ្ញុំបានឈ្លោះជាមួយអ្នករត់តាស៊ីម្នាក់។

ខ្ញុំពិតជាអរព្រះគុណព្រះអង្គណាស់ ដែលគ្មានអ្នកណាគិតថាខ្ញុំជាមនុស្សអត់បានការ និងគិតថា ៥ឆ្នាំទៀតខ្ញុំនឹងធ្វើការលែងកើត ដោយព្រោះតែភាពស្រវឹងជោកជាំរាល់ថ្ងៃរបស់ខ្ញុំ។ ចំណែកប្រពន្ធខ្ញុំវិញ គាត់បានទៅធ្វើការនៅហាងធំៗ ពេលគាត់មកដល់ផ្ទះវិញឃើញខ្ញុំស្រវឹងរហូតអ៊ីចឹង ធ្វើឲ្យគាត់អស់កំលាំងទាំងកាយទាំងចិត្ត។ សំរាប់ខ្ញុំ វិញស្រាថ្លៃៗមិនសំខាន់ទេ សំខាន់គឺមានស្រាផឹក។ ពេលដាច់ថៃ ទោះស្រាស ឬស្រាថ្នាំក៏ដោយគង់តែស្រវឹងដូចគ្នា។ ពេលខ្ញុំរកលុយបានពីរបីរយដុល្លារមក គឺសំរាប់តែសងថ្លៃស្រាតាមបារ តាមហាងតែប៉ុណ្ណោះ។ រាល់ពេលក្រោកពីគេងពេលព្រឹក ខ្ញុំចេះតែញ័រខ្លួន ត្រូវការដកមេ១ចូលាយបីយ៉ៃរ៥កំប៉ុងមុនបាយព្រឹកជាប្រចាំ។

ទោះជាយ៉ាងនេះក្តី ខ្ញុំនៅតែគិតថា ខ្ញុំអាចគ្រប់គ្រងស្ថានភាពបាន ហើយប្រពន្ធរបស់ខ្ញុំក៏សង្ឃឹមថា ខ្ញុំបានធូស្បើយក្នុងការផឹកស្រានេះដែរ។ ផ្ទុយស្រឡះពីនោះ ស្ថានភាពរបស់ខ្ញុំចេះតែដុនដាបទៅៗ។ ផ្ទះរបស់ខ្ញុំត្រូវគេរឹបអូសយក ម្តាយក្មេករបស់ខ្ញុំបានស្លាប់ ប្រពន្ធនិងឪពុកក្មេករបស់ខ្ញុំបានធ្លាក់ខ្លួនឈឺ។ ក្រោយមកទៀត ខ្ញុំក៏មានឱកាសធ្វើជំនួញមួយដ៏ជាទីសង្ឃឹម។ ខ្ញុំបានបង្កើតក្រុមមួយដើម្បីទិញភាគហ៊ុនដែលកំពុងតែធ្លាក់ចុះនាឆ្នាំ១៩៣២។ ពេលនោះខ្ញុំបានចំណេញលុយគួរជាទីពេញចិត្ត បន្ទាប់មកខ្ញុំកាន់តែលាប់ស្រាខ្លាំងជាងមុន បណ្តាលឲ្យបាត់បង់ឱកាសរកលុយទៀត។ ខ្ញុំភ្ញាក់ខ្លួន ហើយបានសំរេចចិត្តថា ខ្ញុំត្រូវតែឈប់ផឹក។ ខ្ញុំស្បថថាខ្ញុំមិនផឹកសូម្បីតែមួយកែវ។ខ្ញុំបានឈប់ផឹកមែន។ ពីមុនខ្ញុំក៏ធ្លាប់សន្យាជាមួយប្រពន្ធខ្ញុំជាច្រើនលើកច្រើនសា ប៉ុន្តែម្តងនេះ ប្រពន្ធរបស់ខ្ញុំសង្កេតឃើញថា ខ្ញុំនិយាយពិតមែន។

ថ្ងៃមួយ ពេលខ្ញុំមកដល់ផ្ទះវិញទាំងស្រវឹងដោយមិនដឹងខ្លួន វាហាក់គ្មានអ្វីមួយមកខ្សឹបប្រាប់ខ្ញុំ ឬហាមខ្ញុំសោះក្នុងការឈប់ផឹកស្រានេះ។ តើការប្ដេជ្ញាចិត្តរបស់ខ្ញុំនៅណា? ខ្ញុំមិនដឹងទាល់តែសោះ ខ្ញុំនឹកមិនឃើញទេ។ ពេលមានគេជំរុញឲ្យខ្ញុំដាក់មួយតយ ខ្ញុំក៏ដាក់មួយតយតាមគេ។ តើខ្ញុំឆ្កួតមែនឬ? ខ្ញុំមិនដឹងមកពីហេតុអ្វីទេ ខ្ញុំឆ្ងល់ណាស់អំពីការប្ដេជ្ញាចិត្តក្នុងការឈប់ផឹកស្រារនេះ។

ខ្ញុំបានព្យាយាមតាំងអារម្មណ៍ឈប់ម្ដងទៀត។ ដោយមានជំនឿចិត្តលើខ្លួនឯងខ្លាំងពេក វាធ្វើឲ្យខ្ញុំខ្លាយជាមានអំនួតទៅវិញ ពេលខ្ញុំដើរកាត់ហាងរីបារ ខ្ញុំតែងតែប្រើទឹកមុខសើចឌឺថា ខ្ញុំអាចឈប់ផឹកស្រាបាន។ នៅថ្ងៃមួយ ខ្ញុំបានចូលហាងមួយ ក្នុងគោលបំណងគ្រាន់តែចង់ប្រើទូរស័ព្ទសាធារណៈតែប៉ុណ្ណោះ ប៉ុន្តែដឹងអី ខ្ញុំបែជាទៅអង្គុយផឹកស្រាក្នុងហាងនោះដោយមិនដឹងខ្លួន ហើយខ្ញុំភ្ញាក់ និងសួរខ្លួនឯងថា″ហេតុអ្វីខ្ញុំបែជាមកអង្គុយផឹកស្រានៅទីនេះអ៊ីចឹង? ម៉េចបានទៅជាអ៊ីចឹង?″ ខ្ញុំបានតាំងចិត្តហើយ ប្ដេជ្ញាចិត្តហើយ។ លើកក្រោយខ្ញុំត្រូវតែគ្រប់គ្រងខ្លួនឯងឲ្យបាន ប៉ុន្តែឥឡូវនេះ បានជាជ្រុលតែដាក់ហើយ ដាក់ឲ្យវាជោគតែម្ដងទៅ។

លុះព្រឹកឡើង វិប្បដិសារីយ៍ សេចក្ដីតក់ស្លុត និងក្ដីអស់សង្ឃឹម ដែលខ្ញុំមិនអាចបំភ្លេចបាន គឺខ្ញុំខ្សោយក្នុងការយកឈ្នះលើការផ្ដាច់ស្រា និងការតាំងចិត្ត។ ខួក្បាលខ្ញុំវិលវល់ ព្រមទាំងមានវិបត្តិផ្លូវចិត្តដ៏ធ្ងន់ធ្ងរទៀតផង។ ខ្ញុំស្ទើរតែពុំហ៊ានដើរលើផ្លូវថ្នល់ ក្រែងលោដួល ហើយត្រូវឡានកិន។ ដោយអារម្មណ៍ភ័យខ្លាចញ្រាប់ញ័រដូច្នេះ ខ្ញុំមានតែចូលបារផឹករហូតទល់ភ្លឺ ដើម្បីសម្រួលអារម្មណ៍និងឲ្យអារម្មណ៍មានភាពនឹងនរឡើងវិញ។ ក្នុងកាសែតគេនិយាយពីទីផ្សារភាគហ៊ុន ពេលខ្លះធ្លាក់ចុះ ពេលខ្លះរាងរើបឡើងវិញ ចំណែកខ្ញុំវិញធ្លាក់ចុះដែរ តែមិនរើបឡើងវិញសោះ។ នោះជាគំនិតដ៏ស្មុគស្មាញមួយចំពោះរូបខ្ញុំ។ បើដូច្នោះ តើខ្ញុំគួតែសម្លាប់ខ្លួន ឬយ៉ាងណា? ទេ! ខ្ញុំមិនគួសម្លាប់ខ្លួនទេ។ ទោះបីជាខ្ញុំមានអារម្មណ៍អាប់អួរយ៉ាងណាក៏ដោយ ក៏នៅមានស្រាធ្វើឲ្យអារម្មណ៍ខ្ញុំបានធូរស្រាលដែរ ហេតុដូច្នេះមានតែផឹក ៗរហូតដល់លែងដឹងខ្លួន។

ជីវិតរបស់ខ្ញុំ ត្រូវរងនូវការឈឺចាប់អស់រយៈពេលពីរឆ្នាំបន្ថែមទៀត គឺទាំងផ្លូវកាយនិងផ្លូវចិត្ត។ រាល់ព្រឹកក្រោយពេលក្រោកពីគេង ខ្ញុំដូចជាមនុស្សឆ្កួត ភ័យផង ញ័រផងរកតែស្រាផឹក។ ខ្ញុំតែងតែយកលុយពីកាបូបប្រពន្ធ ដើម្បីទិញស្រាផឹក។ ពេលកំពុងស្រវឹងស្រៀង១ ជួនកាលខ្ញុំបានទៅឈរនៅមាត់បង្អួច ឬនៅមុខកញ្ចក់ក្នុងបន្ទប់ទឹក ពេលខ្លះ ខ្ញុំតែងតែស្ដីបន្ទោសខ្លួនឯងថា ″ហេតុអ្វីក៏ខ្ញុំកំសាកអីកំសាកយ៉ាងនេះ មិនហានលោត ឬផឹកថ្នាំបំពុលក្នុងបន្ទប់ទឹកអោយស្លាប់តែម្ដងទៅ″។ ខ្ញុំបានតែបន្ទោសខ្លួនឯង តែខ្ញុំកំសាកខ្លាចស្លាប់ណាស់ ដល់ថ្នាក់យកពូកមកដាក់នៅជាន់ក្រោម ក្រែងលោថ្ងៃណាមួយខ្ញុំលោតមែន។ ខ្ញុំ

ក្លាយជាមនុស្សវង្វេងស្មារតី ឈឺចុកចាប់ទាំងផ្លូវកាយនិងផ្លូវចិត្ត រហូតដល់ប្រពន្ធខ្ញុំនាំខ្ញុំភៀសខ្លួនទៅរស់នៅឯជនបទ។ ដោយសារខ្ញុំមានភាពឈឺចាប់ខ្លាំងពេក គ្រូពេទ្យក៏បានឲ្យថ្នាំបន្ធូរការឈឺចាប់មកខ្ញុំ។ ខ្ញុំលេបថ្នាំ ក្លែមស្រា មានអី! បិះស្លាប់។ គេព្រួយពីការឆ្កួតវង្វេងរបស់ខ្ញុំនេះខ្លាំងណាស់។ ពេលខ្ញុំផឹក ខ្ញុំមិនសូវស៊ី ឬអត់ស៊ីអីសោះក៏មាន ។ ខ្ញុំបានស្រកអស់១៨គីឡូក្រាម មើលទៅឃើញសុទ្ធតែឆ្អឹង។

ជាបុណ្យកុសល ខ្ញុំមានប្អូនថ្លៃជាគ្រូពេទ្យ និងម្ដាយដែលមានចិត្តសប្បុរស។ ពួកគេបានបញ្ជូនខ្ញុំទៅមន្ទីរពេទ្យដ៏ល្បីឈ្មោះមួយក្នុងស្រុក ដើម្បីទទួលការព្យាបាល ទាំងផ្នែកសម្បទា និងជំងឺញៀនស្រា។ តាមរយៈការប្រើថ្នាំបុរាណ ខួរក្បាលរបស់ខ្ញុំក៏បានធូរស្បើយ ឯវិធីព្យាបាលតាមលំហាត់ប្រាណបានជួយខ្ញុំយ៉ាងច្រើន។ វាជាការល្អ ដែលមានគ្រូពេទ្យដ៏ចំណានម្នាក់ បានប្រាប់ឲ្យខ្ញុំដឹងថា ខ្ញុំមានជំងឺធ្ងន់ធ្ងរទាំងផ្លូវកាយនិងផ្លូវចិត្ត។

វាធ្វើឲ្យខ្ញុំធូរស្រាលផ្លូវចិត្តខ្លះៗដោយដឹងថា "ខ្ញុំជាមនុស្សល្ងង់ និងអាត្មានិយម"។ អ្នកញៀនស្រាមានឆន្ទៈ និងការតាំងចិត្តខ្លាំង តែក្នុងរឿងខ្លះៗប៉ុណ្ណោះ តែបែរជាទន់ខ្សោយក្នុងការយកឈ្នះលើការញៀនស្រាទៅវិញ។ ពេលគេពន្យល់គាត់ ធ្វើឲ្យគាត់ដឹងថា ការតាំងចិត្តដោយខ្លួនឯង វាខ្សោយមិនអាចឈប់ផឹកស្រាបាននោះទេ នេះជាស្ថានភាពអ្នកញៀនស្រា។ ឥឡូវនេះខ្ញុំបានយល់ច្បាស់ ហើយខ្ញុំមានក្តីសង្ឃឹមខ្ពស់។ រយៈពេលបី ឬបួនខែនេះ បានធ្វើអោយមនុស្សល្ងីល្ងើម្នាក់នេះមានសេចក្តីសង្ឃឹមឡើងវិញ។ ហើយខ្ញុំបានត្រឡប់ទៅទីក្រុងរកលុយខ្លះៗជារឿយៗផងដែរ។ ខ្ញុំគិតថាការស្គាល់ខ្លួនឯងវាជាដំណោះស្រាយមួយ។

មានថ្ងៃមួយ ខ្ញុំចាប់ផ្តើមផឹកម្តងទៀត ម្តងនេះវាកាន់តែធ្វើឲ្យសុខភាពផ្លូវកាយ ផ្លូវចិត្តរបស់ខ្ញុំដុនដាបទៅៗ រហូតដល់ថ្នាក់ចូលមន្ទីរពេទ្យម្តងទៀត។ ខ្ញុំគិតថា ម្តងនេះខ្ញុំពិតជាស្លាប់មិនខាន ព្រោះខ្ញុំលឺគេប្រាប់ប្រពន្ធខ្ញុំថា "ប្ដីអ្នកស្រីរស់មិនបានយូទេ ប្រហែលជាមួយឆ្នាំទៀត បើមិនស្លាប់ដោយសាគាំងបេះដូងក៏ស្លាប់ដោយសារដាច់សសៃឈាមក្នុងខួរក្បាលដែរ ឲ្យនៅតែញៀនស្រាបៀបហ្នឹង"។ ប្រពន្ធខ្ញុំឆ្អែតចិត្តហើយហត់នឿយនឹងខ្ញុំមែនទែនហើយ។ គាត់មានជំរើសពីរសំរាប់ខ្ញុំ "បើមិនចូលពេទ្យឆ្កួតទេ មានតែចូលមឈូស"។ ខ្ញុំដឹងថា នេះជាបញ្ហាធ្ងន់ធ្ងរដែលកំពុងបំផ្លាញមោទនភាព និងធ្វើឲ្យខ្ញុំងើបមុខលែងរួច។ ព្រោះជារឿយៗខ្ញុំតែងតែគិតថា ខ្ញុំមានសមត្ថភាពអាចប្រឈមមុខនឹងបញ្ហាជាច្រើនបាន ប៉ុន្តែចុងក្រោយខ្ញុំបែរជាត្រូវដួលចុះទៅវិញ។ ឥឡូវខ្ញុំកំពុងតែធ្លាក់ខ្លួនក្នុងសេចក្តីងងឹត ដើរដង្ហែទៅរកផ្លូវមរណៈជាមួយនឹងអ្នកប្រមឹកជាច្រើនទៀត។ ពេលនេះខ្ញុំមានអារម្មណ៍ថា ខ្ញុំជិតស្លាប់ហើយ ខ្ញុំនឹកអាណិតដល់ប្រពន្ធកំសត់របស់ខ្ញុំណាស់។ ខ្ញុំសោកស្តាយមែនទែនដែលមិនទាន់បាននិយាយសុំទោស នឹងធ្វើល្អចំពោះប្រពន្ធខ្ញុំ។ នឹក

ឃើញអតីតកាលដែលយើងមានពេលសប្បាយជាមួយគ្នា តែឥឡូវអស់ពេលហើយសំរាប់ខ្ញុំ គ្មានឱកាស នឹងធ្វើល្អសំរាប់ប្រពន្ធ និងលែងមានពេលស្បាយជាមួយគ្នាទៀតហើយ។ ខ្ញុំតូចចិត្ត អស់សង្ឃឹម និងសោក ស្តាយមែនទែន។ សេចក្តីស្លាប់បានហំព័ទ្ធជីវិតខ្ញុំ នេះដោយសារតែខ្ញុំមិនអាចយកឈ្នះការញៀនស្រាបា ន។ ខ្ញុំឆ្អែតចិត្តខ្លាំងណាស់ដែលបណ្តោយឲ្យស្រាធ្វើជាម្ចាស់លើជីវិតខ្ញុំ។

មួយរយៈក្រោយមកខ្ញុំចេញពីមន្ទីរពេទ្យទាំងញញ៉ីញញ៉រ ដូចមនុស្សអស់សង្ឃឹមក្នុងឆាកជីវិត។ ដោយការភ័យខ្លាចនឹងសេចក្តីស្លាប់ ខ្ញុំក៏ផ្អាកផឹកស្រា ប៉ុន្តែវាមិនបានទាំងស្រុងទេ។ ថ្ងៃមួយនៅក្នុងពិធីជប់ លាងអបអរសាទរថ្ងៃបុណ្យជាតិ ខ្ញុំភ្លេចខ្លួន ក៏ជ្រុលផឹកទៀត។ ពេលនោះ អ្នកស្គាល់ខ្ញុំគ្រប់គ្នា គិតថា គួតែ ចាប់ខ្ញុំឃុំទុកកន្លែងណាមួយ បើមិនអ៊ីចឹងទេ ខ្ញុំមុខតែជួបមហន្តរាយធំជាពុំខាន។ ខ្ញុំគិតថា នេះគឺជាការ ស្រវឹងចុងក្រោយរបស់ខ្ញុំ វាដូចសុភាសិតមួយនិយាយថា"មេឃភ្លឺបន្ទាប់ពីមេឃងងឹត(ក្រោយភ្លៀង មេឃ ស្រឡះ)"។ តាមសុភាសិតនេះខ្ញុំគិតថា មិនយូប៉ុន្មាន ខ្ញុំនឹងមានសុភមង្គល មានសេចក្តីសុខសាន្ត និង មានជីវិតល្អប្រសើរឡើងវិញនៅថ្ងៃណាមួយជាមិនខាន។

ថ្ងៃមួយពេលខ្ញុំកំពុងអង្គុយផឹកនៅផ្ទះបាយ ខ្ញុំគិតថា គួរតែលាក់ស្រាមួយដបទុកសំរាប់ផឹកនៅព្រឹក ស្អែកទៀត រំពេកនោះ ស្រាប់តែមានគេទូរស័ព្ទមក ធ្វើឲ្យខ្ញុំដាច់អារម្មណ៍អស់។ ខ្ញុំភ្ញាក់ផ្អើលមែនទែន ព្រោះមិត្តចាស់របស់ខ្ញុំម្នាក់បានទូរស័ព្ទមកខ្ញុំ ហើយក៏គួឲ្យចំលែកដែរ ព្រោះសំលេងគាត់ខុសពីមុនឆ្ងាយ លែងជាមនុស្សឡប់ឡែដូចមុនទៀតហើយ។ ពេលមុនៗ គាត់ស្រវឹងគ្មានលោះថ្ងៃសោះ គាត់ស្រវឹងដល់ ថ្នាក់គេយកគាត់ទៅដាក់នៅពេទ្យឆ្កួតទៀតផង។ ប្រហែលជាគាត់រត់ចេញពីមន្ទីរពេទ្យ ហើយទូរស័ព្ទមក បបួលខ្ញុំផឹកហើយមើលទៅ។ ការនេះធ្វើអោយខ្ញុំសប្បាយចិត្តមែនទែន។ បើសិនពួកយើងជួបគ្នា ស៊ីផឹក បង្កើតបរិយាកាសសប្បាយៗ រំលឹកពីអនុស្សាវរីយ៍ចាស់ៗដែលយើងធ្លាប់មានពីអតីត ដូចជា ជួលយន្ត ហោះជិះដើរលេងស៊ីផឹកទៅណេះទៅណោះជាមួយគ្នា មិនដឹងជាសប្បាយចិត្តយ៉ាងណាទេណ៎។ គ្រាន់តែ នឹកឃើញក៏សប្បាយដែរ សមឥឡូវកំពុងតែធុញថប់តប់ប្រម៉ល់ផង។

រំពេចនោះ ទ្វារក៏របើក ហើយខ្ញុំឃើញគាត់ឈរនៅមាត់ទ្វាទាំងមានទឹកមុខស្រស់ស្រាយ។ គាត់ជា មនុស្សខុសប្លែកពីអ្វីដែលខ្ញុំបានគិត។ តើមានអ្វីកើតឡើងចំពោះគាត់? ពេលគាត់អង្គុយនៅតុជាមួយខ្ញុំ ខ្ញុំ បានឲ្យស្រាគាត់មួយកែវ ប៉ុន្តែគាត់មិនផឹកទេ។ ខ្ញុំអន់ចិត្តណាស់ ហេតុអ្វីបានជាគាត់មិនផឹកអ៊ីចឹង ខ្ញុំឆ្ងល់ ណាស់ ហេតុអ្វីបានជាគាត់មិនដូចពីមុន! ខ្ញុំសួរគាត់ថា តើមានអ្វីកើតឡើងចំពោះឯង? គាត់បានឆ្លើយថា គាត់បានជឿលើព្រះហើយ។ ខ្ញុំស្រឡាំងកាំងតែម្តង ពេលឮដូច្នោះ។ ពីព្រោះកាលពីរដូវក្តៅឆ្នាំមុន គាត់ជា អ្នកប្រមឹកម្នាក់ ចុះហេតុអ្វីបានជាគាត់អាចជឿលើព្រះបាន។ ពីមុនគាត់ឆ្កួតនឹងស្រា តែឥឡូវគាត់បែរជា

ឆ្កួតនឹងសាសនាទៅវិញ។ ណ្ហើយ សូមព្រះអង្គប្រទានពរគាត់ចុះ។ បើគាត់គ្រាន់តែមកដើម្បីអធិប្បាយពីព្រះអោយខ្ញុំស្តាប់ ក៏អធិប្បាយទៅចុះ។ ហើយបើទោះជាគាត់អធិប្បាយយូរប៉ុណ្ណាក៏យូរទៅចុះ ឲ្យតែខ្ញុំមានស្រាផឹកទៅបានហើយ។ ប៉ុន្តែអ្វីដែលកើតឡើងនោះ វាផ្ទុយស្រឡះពីអ្វីដែលខ្ញុំគិត គាត់មិនបានអធិប្បាយអ្វីច្រើនទេ គាត់បែរជានិយាយពីបទពិសោធន៍របស់គាត់ ក្នុងតុលាការ ក្រោមការជំនុំជម្រះរបស់ចៅក្រមទៅវិញ។ គាត់បន្តទៀតថា ពេលនោះមានបុរសពីរនាក់បានមកបំភ្លឺឲ្យគាត់នៅមុខចៅក្រម ដើម្បីសុំចៅក្រមលើកលែងការចោទប្រកាន់ដល់គាត់។ បុរសពីរនាក់នោះបានប្រាប់ពីការគ្រប់គ្រងអារម្មណ៍តាមបែបសាសនា និងការនុវត្តន៍សកម្មភាពសាមញ្ញៗដល់គាត់។ ការនេះវាកើតឡើងកាលពីពីរខែមុនប៉ុណ្ណោះ។ ឥឡូវនេះ គាត់ប្រែមកជាមនុស្សប្រក្រតីវិញហើយ។ តាមពិតមិត្តភក្តិខ្ញុំមក ដើម្បីចែករំលែកបទពិសោធន៍ដែលគាត់បានឆ្លងកាត់កន្លងមកអោយខ្ញុំដឹង។ ពេលខ្ញុំឮរឿងរ៉ាវទាំងនោះ ធ្វើឲ្យខ្ញុំមានការភ្ញាក់ផ្អើល និងចាប់អារម្មណ៍ស្តាប់យ៉ាងខ្លាំង ពីព្រោះខ្ញុំជាមនុស្សអស់សង្ឃឹមម្នាក់ក្នុងជីវិត ដែលមិនអាចផ្តាច់ស្រាបាន។ គាត់បាននិយាយជាមួយខ្ញុំអស់ជាច្រើនម៉ោង ហើយការនោះធ្វើឲ្យខ្ញុំនឹកឃើញរឿងរ៉ាវកាលខ្ញុំនៅក្មេង។ ខ្ញុំចាំសម្តីគ្រូអធិប្បាយម្នាក់ ប្រាប់ឲ្យក្រុមជុំនុំ ធ្វើកិច្ចសន្យាអត់ផឹកស្រា តែខ្ញុំមិនបានធ្វើតាមនោះទេ។ តាខ្ញុំឮគេនិយាយខ្សឹបខ្សៀវគ្នាពីការនោះនៅព្រះវិហារ ធ្វើឲ្យគាត់អស់សំណើច និងសើចចំអកឲ្យពួកគេយ៉ាងខ្លាំង។ គាត់បានខ្សឹបប្រាប់ខ្ញុំថា គាត់មិនចូលចិត្តធ្វើអ្វីតាមគ្រូគង្វាលប្រាប់នោះទេ គ្រូគង្វាលគ្មានអំណាច ឬគ្មានសិទ្ធិអ្វីមកបញ្ជាយើងឡើយ។ គាត់តែងតែមិនពេញចិត្តចំពោះកម្មវិធីផ្សេងៗ ដែលព្រះវិហារបានរៀបចំ។

មុនតាខ្ញុំជិតដាច់ខ្យល់ស្លាប់ គាត់នៅតែមមើលមមាយ សើចចំអកឲ្យក្រុមជំនុំទៀត។ ការទាំងនោះបានជះឥទ្ធិពលមិនល្អដល់ខ្ញុំ ក្នុងការទទួលជឿព្រះ។ ទន្ទឹមនឹងនោះ វាក៏រំលឹកខ្ញុំ ពីសិលាចារឹតនៅព្រះវិហារ វិនធេស្ទើរ ដែលខ្ញុំធ្លាប់បានទៅកាលពីមុន។ សំណេរនោះ ហាក់ដូចជាការព្រមានដល់ខ្ញុំដូច្នោះដែរ។ កាលពីដើមឡើយខ្ញុំជឿលើអំណាចមួយដែលធំជាងខ្ញុំ ហើយព្រះអង្គបានរំលឹកខ្ញុំតាមការព្រមាននោះ។

ខ្ញុំក៏ជាអ្នកជឿព្រះម្នាក់ដែរ ប៉ុន្តែមិនមែនដូចប្រភេទមនុស្សមួយចំនួនដែលជឿផ្កាប់មុខនោះឡើយ។

អ្នកប្រាជ្ញ អ្នកវិទ្យាសាស្ត្រ អ្នកបដិវត្តខ្លះយល់ឃើញថា ពិភពលោកនេះកើតឡើង គឺគ្មានគោលបំណងអ្វីច្បាស់លាស់នោះទេ វាគ្រាន់តែជាការកើតឡើងដោយចៃដន្យប៉ុណ្ណោះ តែគេជឿលើច្បាប់ធម្មជាតិ។

តើពិភពលោកទាំងមូល ពិតជាកើតឡើងដោយចៃដន្យ ឬមានអ្នកបង្កើតវាឡើងប្រកបដោយគំរោងការដ៏អស្ចារ្យ? ទេ! វាត្រូវតែមានអំណាចមួយជាអ្នកបង្កើតវាឡើង វាមិនអាចកើតឡើងដោយចៃដន្យនោះទេ។ ហេតុផលនេះហើយដែលខ្ញុំជឿថា ប្រាកដជាមានអំណាចដ៏ធំមួយមែន។ ខ្ញុំពិតជាជឿថា មានអំណាចអស្ចារ្យមួយមែន ប៉ុន្តែខ្ញុំមិនបានអភិវឌ្ឍន៍សេចក្តីជំនឿរបស់ខ្ញុំអោយបានស្គាល់អំណាចនោះកាន់តែច្បាស់នោះឡើយ។ ឲ្យតែគេនិយាយពីរឿងសាសនា និងព្រះមកកាន់ខ្ញុំ វាធ្វើឲ្យខ្ញុំមានអារម្មណ៍តឹងតែង អន់ចិត្ត ខឹង ហើយបិទចិត្តមិនព្រមស្តាប់ និងជឿតាមតែម្តង។

ព្រះយេស៊ូ គឺជាបុគ្គលដ៏អស្ចារ្យម្នាក់មែន ប៉ុន្តែអស់អ្នកដែលជឿលើទ្រង់ មានការលំបាកក្នុងការប្រព្រឹត្តអោយបានដូចទ្រង់។ ការបង្រៀនរបស់ទ្រង់ពិតជាមានសារៈប្រយោជន៍ណាស់ ប៉ុន្តែចំពោះខ្ញុំផ្ទាល់ ខ្ញុំអនុវត្តតាមតែមេរៀនណាដែលស្រួលប៉ុណ្ណោះ ចំណែកមេរៀនពិបាកៗ ខ្ញុំបោះចោលមិនធ្វើតាមទេ។

តាមរយៈសង្គ្រាម ការអុជអាល ការបោកប្រាស់ និងជម្លោះសាសនា នានា បានធ្វើឲ្យខ្ញុំឆ្អែតចិត្តលែងចង់ដឹង ចង់លឺពីរឿងសាសនាតែម្តង ព្រោះ សង្គ្រាមនៅអឺរ៉ុប ខ្ញុំមិនបានឃើញព្រះធ្វើការអ្វីសោះដើម្បីដោះស្រាយបញ្ហាមនុស្សលោក។ មួយវិញទៀត បើពិតជាមានអារក្សសាតាំងមែន នោះវាគឺជាម្ចាស់ពិភពលោកនេះ ហើយខ្ញុំក៏ជាសិស្សរបស់វាដែរ នោះខ្ញុំនឹងនៅក្រោមអំណាច និងការគ្រប់គ្រងរបស់វាមិនខាន។

មិត្តខ្ញុំដែលកំពុងអង្គុយទល់មុខខ្ញុំ បាននិយាយថា ព្រះជាម្ចាស់បានជួយគាត់នូវអ្វីដែលគាត់មិនអាចធ្វើខ្លួនឯងបាន។ តាមការខំប្រឹងប្រែងដោយខ្លួនឯង វាគ្មានប្រសិទ្ធិភាពទេ។ គ្រូពេទ្យក៏បញ្ជាក់ដែរថា គេមិនអាចព្យាបាលជម្ងឺឲ្យគាត់បានជាដែរ មានតែយកគាត់ទៅដាក់នៅមន្ទីរពេទ្យឆ្កួតប៉ុណ្ណោះ។ នៅចំពោះមុខខ្ញុំ គាត់បានសារភាពថា ជីវិតរបស់គាត់បរាជ័យទាំងស្រុង តែពេលនេះ ជីវិតរបស់គាត់ដូចរួចពីសេចក្តីស្លាប់ ដូចត្រូវបានគេរើសយកមកពីធុងសំរាមវិញអ៊ីចឹង។ ឥឡូវនេះ ជីវិតរបស់គាត់បានប្រសើរឡើងវិញហួសពីការគិតទៅទៀត។ តើអំណាចនេះមកពីណា? វាមកពីខាងក្នុងគាត់ឬមិនមែន? តាមពិតគាត់ដូចជាខ្ញុំអ៊ីចឹងដែរ ខ្ញុំគ្មានអំណាចអ្វីសោះ គាត់ក៏អត់មានអំណាចអ្វីដែរ តើអំណាចនេះមកពីណា? រឿងនេះវាពិតជាធ្វើឲ្យខ្ញុំភ្ញាក់ផ្អើលខ្លាំងមែនទែន។ តាមរយៈសាសនាហាក់ដូចជានិយាយសមហេតុផលម្យ៉ាងដែរ។ ពីមុន ខ្ញុំមិនជឿលើការអស្ចារ្យអ្វីនោះទេ តែឥឡូវនេះ វាធ្វើឲ្យខ្ញុំបានឃើញពីការអស្ចារ្យមួយដែលកំពុងតែអង្គុយខាងមុខខ្ញុំស្រាប់។ វាពិតជាអស្ចារ្យមែន ដែលគាត់ទទួលបាននូវការផ្លាស់ប្រែដូច្នេះ។

ទោះបើខ្ញុំឃើញគំរូល្អរបស់មិត្តភក្តិខ្ញុំក៏ដោយ ក៏ខ្ញុំនៅតែប្រកាន់គំនិតអគតិចំពោះការនោះដដែល។ ពេលលឺពាក្យថា" ព្រះជាម្ចាស់" វាហាក់ធ្វើឲ្យខ្ញុំអត់ស្រួលក្នុងអារម្មណ៍ទាល់តែសោះ។ ពេលដែលគេប្រាប់ខ្ញុំពីគំនិតថាមានព្រះសង្គ្រោះមួយអង្គ វាធ្វើឲ្យខ្ញុំមានការទើសទាល់ក្នុងចិត្តខ្លាំងមែនទែន ពីព្រោះខ្ញុំមិនចូល

ចិត្តទស្សនៈបែបនោះទាល់តែសោះ។ ខ្ញុំចូលចិត្តលើទស្សនៈមួយដែលថា មានវិញ្ញាណដ៏មានអំណាចមួយបានប្រដិដ្ឋធម្មជាតិនេះឡើង។ ខ្ញុំចូលចិត្តទស្សនៈ បែបសកល ឬលើវិញ្ញាណដែលគ្រប់គ្រងលើធម្មជាតិ ប៉ុន្តែខ្ញុំប្រកាន់ដាច់ខាតចំពោះទស្សនៈដែលថាមានព្រះដែលជាស្តេចនៃឋានសួគ៌ ទោះបើទ្រង់ល្អយ៉ាងណាក៏ដោយ។

ពួកម៉ាក់ខ្ញុំបានឲ្យយោបល់ខ្ញុំដូចជាគំនិតនៅក្នុងរឿងប្រលោមលោកអ៊ីចឹង គឺគាត់ប្រាប់ខ្ញុំថា "ហេតុអ្វីបានជាឯងមិនជ្រើសរើសទស្សនៈណាមួយអំពីព្រះដែលសក្តិសមនឹងឯងបំផុតទៅ?

ពាក្យសំដីមួយម៉ាត់នេះប៉ះពាល់ចិត្តខ្ញុំយ៉ាងខ្លាំង។ វាហាក់បីដូចជាកម្តៅដែលកំពុងរំលាយភ្នំទឹកកកដែលបានតាំងជាម្លប់ដ៏រឹងមាំសំរាប់ខ្ញុំអស់រាប់ឆ្នាំ ឲ្យរលាយត្រឹមតែមួយរំពេចភ្នែក។ ទីបំផុតខ្ញុំបានឈរក្រោមកំដៅថ្ងៃយ៉ាងពិតប្រាកដ។ ឥឡូវនេះវាមិនស្មុគស្មាញប៉ុន្មានទេ ខ្ញុំគ្រាន់តែជឿលើមេអំណាចមួយដែលធំជាងខ្ញុំប៉ុណ្ណោះ។ នេះជាជំហានទីមួយ វាជាការចាប់ផ្តើមមួយដែលគ្មានអ្វីផ្សេងក្រៅពីហ្នឹងឡើយក្នុងជំហានដំបូងនេះ។ ខ្ញុំយល់ថា ភាពលូតលាស់អាចចាប់ផ្តើមពីត្រង់នេះទៅ។ ការសុខចិត្តជឿលើមេអំណាចមួយ គឺជាមូលដ្ឋានគ្រឹះក្នុងការកសាងជីវិត ដូចអ្វីដែលខ្ញុំបានឃើញក្នុងជីវិតមិត្តភក្តិខ្ញុំអ៊ីចឹងដែរ។ តើខ្ញុំធ្វើអ៊ីចឹងបានរឺអត់? បាន! ខ្ញុំពិតជាអាចធ្វើបាន។

ខ្ញុំជឿថា ព្រះជាម្ចាស់ខ្វល់ខ្វាយពីយើង នៅពេលដែលយើងត្រូវការទ្រង់។ ទីបំផុតខ្ញុំបានយល់ ខ្ញុំបានទទួលការប៉ះពាល់ពីព្រះ ហើយខ្ញុំក៏ជឿលើទ្រង់។ ភាពអំនួត និងគំនិតអគតិនិយម បានរលាយបាត់ពីខ្ញុំអស់ហើយ ខ្ញុំបានឃើញពិភពលោកថ្មីស្រឡាងមួយនៅពេលនេះ។ ការនេះរំលឹកខ្ញុំពីអ្វីដែលខ្ញុំបានឆ្លងកាត់កាលពីប៉ុន្មានឆ្នាំមុន គឺវាហាក់បីដូចជាមួយប៉ប្រិចភ្នែកប៉ុណ្ណោះសំរាប់ខ្ញុំកាលនោះ។ ពេលននោះ ខ្ញុំមានអារម្មណ៍ថា ខ្ញុំត្រូវការព្រះ និងចង់បានព្រះ ហើយខ្ញុំក៏សុខចិត្តទទួលព្រះអង្គគង់នៅជាមួយខ្ញុំដែរ។ ព្រះពិតជាមានមែន។ ប៉ុន្តែ បន្តិចក្រោយមក ព្រះវត្តមានរបស់ព្រះជាម្ចាស់ហាក់បានរសាយបាត់ពីខ្ញុំអស់រលីង។ បញ្ហា ការខ្វល់ខ្វាយ ការព្រួយបារម្ភ និងការរំខានស្មារតីនានា បានធ្វើខ្ញុំឲ្យប្រាស់ចាកឆ្ងាយពីព្រះវត្តមានរបស់ព្រះ។ ខ្ញុំសោកស្តាយណាស់ដែលបានបណ្តោយឲ្យខ្លួនឯងស្ថិតក្នុងភាពងងឹត មើលមិនឃើញសេចក្តីពិតបែបនេះ។ ខ្ញុំពិតជាល្ងង់មែន!

នៅមន្ទីពេទ្យរោគចិត្ត គេហាមខ្ញុំមិនឲ្យផឹកស្រាទេ។ ក្នុងស្ថានភាពបែបនេះ ខ្ញុំពិតជាត្រូវការ ការព្យាបាលខ្លាំងណាស់ ពីព្រោះខ្ញុំដឹងពីស្ថាន និងរោគសញ្ញារបស់ខ្លួនឯងថា ខ្ញុំកំពុងតែស្ថិតនៅក្នុងភាពធ្ងន់ធ្ងរ។ ជារឿយៗខ្ញុំតែងតែញ័រសាច់ខ្លាំង និងចេះតែរវើរវាយ។ ខ្ញុំបន្ទាបខ្លួន និងថ្វាយខ្លួនទៅព្រះដែលពោរពេញដោយសេចក្តីស្រលាញ់និងមានព្រះទ័យមេត្តាករុណា។ ខ្ញុំព្រមស្តាប់បង្គាប់ព្រះអង្គ និងអនុញ្ញាតិឲ្យទ្រង់

ដឹកនាំជីវិតរបស់ខ្ញុំ។ ខ្ញុំសារភាពជាលើកដំបូងក្នុងមួយជីវិតរបស់ខ្ញុំថា ខ្ញុំមិនអាចដឹកនាំជីវិតខ្លួនឯងបានទេ បើគ្មានព្រះអង្គ ខ្ញុំពិតជាវង្វេងហើយ។ ខ្ញុំតាំងចិត្តជាថ្មី ហើយក៏ព្រមប្រឈមមុខនឹងអំពើបាបរបស់ខ្លួនឯងដែរ។ ខ្ញុំសុខចិត្តឲ្យមិត្តសំលាញ់ថ្មីរបស់ខ្ញុំ(ព្រះជាម្ចាស់)ដឹកយកអស់ទាំងឫសគល់នៃអំពើបាបចេញពីជីវិតរបស់ខ្ញុំ។ តាំងពីពេលនោះមក ខ្ញុំមិនដែលផឹកស្រាទៀតឡើយ សូម្បីតែមួយដំណក់។

មិត្តរួមសាលាខ្ញុំ បានមកសួរសុខទុក្ខខ្ញុំ ហើយខ្ញុំក៏បានរ៉ាយរ៉ាប់ប្រាប់គាត់ពីបញ្ហាទាំងឡាយដែលកើតមានក្នុងជីវិតរបស់ខ្ញុំ។ យើងបានធ្វើបញ្ជី **អ្នកដែលខ្ញុំធ្លាប់ធ្វើឲ្យគេឈឺចាប់ និងអ្នកដែលខ្ញុំមានគំនុំ និងកំហឹងជាមួយពួកគេ**។ ខ្ញុំមានបំណងចិត្ត និងសុខចិត្តប្រឈមមុខ សារភាពរាល់កំហុសឆ្គងទាំងឡាយដែលខ្ញុំបានប្រព្រឹត្ត ទាំងសុំទោសពួកគេ ហើយក៏ឈប់រកកំហុសគេ និងព្រមផ្សះផ្សារជាមួយពួកគេដោយអស់ពីចិត្ត និងសមត្ថភាពរបស់ខ្ញុំ។

ខ្ញុំបានសាកល្បង បើកចិត្តឲ្យអំណាចព្រះដែលស្ថិតនៅក្នុងខ្ញុំ ជួយវិនិច្ឆ័យចិត្ត គំនិត និងគ្រប់កិច្ចការដែលខ្ញុំធ្វើ។ គំនិតរឹងចចេស ដែលខ្ញុំធ្លាប់មានពីមុននោះ វាគ្មានតម្លៃអ្វីសំរាប់ខ្ញុំទៀតទេនៅពេលនេះ។ ពេលខ្ញុំមានបញ្ហាអ្វីមួយ ឬសង្ស័យក្នុងការសំរេចចិត្តរបស់ខ្ញុំ ខ្ញុំតែងចំណាយពេលស្ងៀមស្ងាត់ជាមួយព្រះអង្គ សុំទ្រង់ប្រទានកំលាំង និងការណែនាំ ដើម្បីអោយខ្ញុំអាចប្រឈមមុខនឹងបញ្ហាដែលខ្ញុំមាននោះ តាមបំណងព្រះហឫទ័យរបស់ទ្រង់។ ខ្ញុំមិនដែលអធិដ្ឋានដើម្បីប្រយោជន៍ផ្ទាល់ខ្លួននោះទេ លើកលែងតែសំណូមពរនោះអាចជាប្រយោជន៍ដល់អ្នកដទៃ។ តាមរយៈការនេះ ខ្ញុំជឿថា ខ្ញុំនឹងទទួលបានព្រះពរពីព្រះដ៏ធំរបស់ខ្ញុំ។(មិនមែនថាធ្វើទៅអត់ទទួលផលនោះទេ)

មិត្តរបស់ខ្ញុំបានសន្យានឹងខ្ញុំថា ប្រសិនបើខ្ញុំអាចធ្វើតាមនិងសំរេចគ្រប់កិច្ចការទាំងអស់នេះបាន ខ្ញុំនឹងមានទំនាក់ទំនងថ្មីជាមួយព្រះជាម្ចាស់។ ហើយខ្ញុំនឹងមានមធ្យោបាយដោះស្រាយបញ្ហាទាំងឡាយបានជាមិនខាន។ ការជឿលើព្រះ ឬអំណាចមួយ ប្រកបដោយឆន្ទៈ ភាពស្មោះត្រង់ និងការបន្ទាបខ្លួន ពិតជាអាចជួយស្តាបនា និងថែរក្សាយើងឲ្យទទួលបាននូវជីវិតថ្មី។ ឯការរស់នៅរបស់យើងទៀតសោត ក៏មានស្ថេរភាព។ ស្តាប់ទៅវាងាយ ប៉ុន្តែវាពិតជាពិបាកធ្វើខ្លាំងណាស់។ គ្រប់អ្វីៗទាំងអស់ត្រូវតែមានការបង់ថ្លៃ។ ខ្ញុំត្រូវតែមានការលះបង់ខ្ពស់ ជាពិសេសគឺត្រូវបំផ្លាញគំនិតអាត្មានិយមចោលឲ្យអស់កុំឲ្យមានទៀត។ ហើយខ្ញុំត្រូវថ្វាយអ្វីៗទាំងអស់ទៅព្រះ ហើយអនុញ្ញាតអោយទ្រង់សោយរាជលើកជីវិតខ្ញុំ។

កិច្ចការទាំងឡាយខាងលើនេះ វាពិតជាពិបាកខ្លាំងណាស់សំរាប់ខ្ញុំ ប៉ុន្តែបើខ្ញុំព្រមបើកចំហដួងចិត្តខ្ញុំ ហើយអនុវត្តកិច្ចការទាំងអស់នេះ វាដូចជាដាស់ព្រលឹងវិញ្ញាណខ្ញុំឲ្យរស់ឡើងវិញអ៊ីចឹង។ ខ្ញុំទទួលបាននូវអារម្មណ៍ជោគជ័យ រួមជាមួយសេចក្តីសុខសាន្តនៅក្នុងចិត្តដែលខ្ញុំមិនធ្លាប់មានពីមុន។ ខ្ញុំមានទំនុកចិត្ត

មានកម្លាំងទឹកចិត្ត និងមានអារម្មណ៍ភ្លឺថ្លា ធូស្រាល ត្រជាក់ចិត្ត ដូចបានស្រូបយកខ្យល់អាកាសដ៏បរិសុទ្ធនៅលើកំពូលភ្នំអ៊ីចឹងដែរ។

ព្រះជាម្ចាស់ធ្វើការក្នុងចិត្តមនុស្សដោយសន្សឹមៗ ប៉ុន្តែឥទ្ធិពលរបស់ព្រះអង្គមកលើរូបខ្ញុំ វាហាក់ដូចជាជនជោរ ជាប់ស្អិត និងជ្រាលជ្រៅយ៉ាងខ្លាំងក្នុងចិត្តរបស់ខ្ញុំ។ ពេលនេះខ្ញុំបានភ្ញាក់ខ្លួន ទាំងមានអារម្មណ៍ថា ខ្លួនឯងប្លែកខុសពីមុន។ ខណៈនោះខ្ញុំក៏ទូរស័ព្ទទៅកាន់មិត្តខ្ញុំម្នាក់ ដែលជាវេជ្ជបណ្ឌិត ដើម្បីសួរគាត់ថា "តើខ្ញុំនៅតែឆ្កួតទៀត ឬយ៉ាងណា"។ គាត់បានស្តាប់នូវអ្វីៗដែលខ្ញុំបានរៀបរាប់ប្រាប់គាត់ គាត់ក៏មានការងឿងឆ្ងល់យ៉ាងខ្លាំងនូវអ្វីដែលបានកើតឡើងចំពោះខ្ញុំ វាមិនគួឲ្យជឿទាល់តែសោះ។ គាត់បានប្រាប់ខ្ញុំថា "ខ្ញុំមិនដឹងថាមានរឿងអ្វីកើតឡើងចំពោះឯងនោះទេ ខ្ញុំគ្រាន់តែដឹងថា សូមឯងកុំបោះបង់ចោលការទាំងអស់ដែលឯងកំពុងធ្វើនេះឡើយ ពីព្រោះវាធ្វើអោយឯងឲ្យល្អជាង**ចឹល**កាលពីមុនទៅទៀត"។

លោកវេជ្ជបណ្ឌិត ស្គាល់បុរសជាច្រើនដែលមានបញ្ហាបែបនេះ។ ពួកគេសុទ្ធតែឆ្លងកាត់រឿងរ៉ាវជីវិតស្រដៀងៗនឹងខ្ញុំដែរ។ ពេលខ្ញុំសំរាកនៅមន្ទីរពេទ្យ ខ្ញុំឃើញ មានអ្នកញៀនស្រារាប់ពាន់នាក់ ហើយខ្ញុំសង្ឃឹមថា គេនឹងសប្បាយ ប្រសិនបើពួកគេមានឱកាសទទួលនូវអ្វីដូចដែលខ្ញុំបានទទួលនោះ។ យ៉ាងហោចណាស់ខ្ញុំអាចជួយគេបានខ្លះៗ ហើយគេនឹងបន្តធ្វើការនេះជាមួយអ្នកញៀញស្រាផ្សេងទៀត។

មិត្តភក្តិខ្ញុំ បានសង្កត់ធ្ងន់ទៅលើសារៈប្រយោជន៍នៃគោលការណ៍នេះថា វាអាចយកទៅអនុវត្តបានគ្រប់ផ្នែកនៃជីវិតរបស់ខ្ញុំ។ មួយវិញទៀត វាក៏សំខាន់ដែរ ប្រសិនបើខ្ញុំចែកចាយបន្តកិច្ចការទាំងអស់នេះជាមួយអ្នកញៀនស្រាដទៃទៀត ដូចដែលគាត់បានធ្វើជាមួយខ្ញុំដែរ។ សេចក្តីជំនឿដែលគ្មានការប្រព្រឹត្ត គឺជាសេចក្តីជំនឿដែលស្លាប់។ ប្រសិនបើអ្នកញៀនស្រា អត់យកចិត្តទុកដាក់ស្ថាបនាជីវិតខាងព្រលឹងវិញ្ញាណ ដោយការប្រព្រឹត្តល្អ និងការលះបង់សំរាប់អ្នកដទៃទេ គាត់មិនអាចឆ្លងកាត់ឧបសគ្គ និងការល្បួងនានាបានឡើយនៅពេលណាគាត់អស់សង្ឃឹម ឬធ្លាក់ទឹកចិត្ត។ ប្រសិនបើគាត់អត់ធ្វើការ គាត់នឹងផឹកស្រាជាថ្មី។ បើសិនគាត់ផឹក គាត់ពិតជាស្លាប់ពុំខានឡើយ ចំណែកឯជំនឿនឹងបាត់បង់ផងដែរ។ នេះជាមេរៀនដែលយើងត្រូវរៀន។ ប្រពន្ធខ្ញុំ និងខ្ញុំបានលះបង់ខ្លួន ជាប្រយោជន៍ជួយដល់អ្នកញៀនស្រាផ្សេងៗទៀតដើម្បីជួយដោះស្រាយបញ្ហារបស់គេ។ ខ្ញុំបានព្យាយាមរកការងារធ្វើអស់រយៈពេល១ឆ្នាំ ប៉ុន្តែនៅតែពុំទាន់រកបាន ពេលនោះសតិអារម្មណ៍ខ្ញុំអត់ស្រួលទេ ខ្ញុំមានអារម្មណ៍ថាអាណិតខ្លួនឯង និងមានគំនុំច្រើនក្នុងចិត្ត។ សតិអារម្មណ៍ខ្ញុំចេះតែចង់នាំខ្ញុំទៅផឹកម្តងទៀត។ ប៉ុន្តែ មិនយូប៉ុន្មានពេលខ្ញុំធ្វើការជាមួយអ្នកញៀនស្រា វាបែរជាមានការលើកទឹកចិត្ត និងសង្គ្រោះខ្ញុំពីការវិលទៅរកជីវិតចាស់វិញ។ ពេលខ្ញុំអស់សង្ឃឹម ខ្ញុំតែងតែទៅលេងមន្ទីរពេទ្យចាស់របស់ខ្ញុំ ដើម្បីជួយអ្នកញៀនស្រាផ្សេងទៀត។ រាល់ពេលដែលខ្ញុំបានជួយ

ពួកគេ វាធ្វើអោយខ្ញុំទទួលបាននូវការលើកទឹកចិត្តខ្លាំង ហើយវាក៏ជួយខ្ញុំបន្តដើរតាមផ្លូវល្អទៀត(ជួយគេ ដូចជួយខ្លួនឯង)។ ការជួយអ្នកដទៃគឺជាផែនការល្អ ដើម្បីជួយខ្លួនឯងនៅពេលណាដែលយើងចង់ផឹក។

យើងបានចាប់ផ្តើមបង្កើតមិត្តភក្តិជាច្រើន ហើយសមាជិកកាន់តែមានច្រើនឡើងៗគួជាទីមោទនភាព។ យើងពិតជាមានសុភមង្គលណាស់ ទោះបើយើងស្ថិតក្រោមសំពាធ និងការលំបាកខ្លាំង ឬច្រើនយ៉ាងណាក៏ដោយ។

ខ្ញុំបានឃើញក្រុមគ្រួសារាប់រយ ដែលពួកគេមានស្មារតីក្រោកឈរឡើងវិញ ឆ្ពោះទៅរកផ្លូវដ៏ត្រឹមត្រូវ និងឃើញស្ថានភាពក្នុងគ្រួសារគេ វិលមករកភាពប្រក្រតីវិញ ពោលគឺ គ្មានជម្លោះ និងភាពល្ងីងល្ងចត់ដូចមុនទៀតឡើយ។ ខ្ញុំបានឃើញបុរសជាច្រើនបានទទួលការព្យាបាលនៅមន្ទីរពេទ្យឆ្កួត ហើយពួកគេក៏មានជីវភាពប្រសើរឡើងវិញ និងបន្តរមានតួនាទីល្អទាំងនៅក្នុងគ្រួសារ និងសង្គម។ ពួកគេមួយចំនួន ជាអតីតអ្នកជំនួញ និងជាអ្នកមានអាជីពផ្សេងៗ ក៏បានស្តាកេរ្តិ៍ឈ្មោះពួកគេឡើងវិញ។ គ្មានអ្វីមួយដែលថាយើងមិនអាចយកឈ្នះបាននោះទេ ទោះបើជាបញ្ហាធំ ឬការលំបាកយ៉ាងណាក៏ដោយ។

មានទីក្រុងមួយនៅភាគខាងលិចសហរដ្ឋ។ នៅជុំវិញតំបន់នោះ មានសមាជិកយើងមួយពាន់នាក់ឯក្រុមគ្រួសារយើងក៏រស់នៅទីនោះដែរ។ ជារឿយៗ យើងជួបគ្នាក្នុងគោលបំណងទាក់ទងអ្នកចំណូលថ្មីឲ្យចូលរួមក្នុងសហគមរបស់យើងដែរ។ ពេលជួបជុំក្រុមម្តងៗ គេឃើញមានអ្នកចូលរួមយ៉ាងហោចណាស់ពី៥០ទៅ២០០នាក់។ សមាជិកកើនឡើងជាលំដាប់ ហើយសមាគមក៏កាន់តែមានឥទ្ធិពល។ (នៅឆ្នាំ២០០៦ សមាគមអ្នកញៀនស្រាអនាមិកមានចំនួនរហូតទៅដល់ ១០៦,០០០ក្រុម (មួយសែនប្រាំមួយពាន់ក្រុម)។

អ្នកញៀនស្រា មិនជាទីគួរាប់អានដល់អ្នកដទៃទេ។ វាពិបាកណាស់ ក្នុងការរក្សាមិត្តភាពជាមួយពួកគេ។ ពេលខ្លះមើលទៅពួកគេ ដូចជាគួឲ្យអស់សំណើច និងពេលខ្លះវាគួឲ្យកំសត់ណាស់។ មានបុរសម្នាក់បានធ្វើអត្តឃាតនៅក្នុងផ្ទះរបស់ពួកយើង ហើយគាត់មិនបានឃើញពីឆាកជីវិតដ៏ថ្លៃថ្នូររបស់ពួកយើងទេ។ ទោះបីជាយ៉ាងនេះក្តី តាមរយៈកិច្ចការដែលពួកយើងបានធ្វើទាំងអស់នេះ បាននាំឲ្យពួកយើងទទួលភាពរីករាយខ្លះៗដែរ។ ពេលមនុស្សខ្លះឮអ៊ីចឹង គេគិតថា ពួកយើងឆ្កួតហើយ រីករាយពេលមានបញ្ហាធ្ងន់ធ្ងរកើតឡើងបែបហ្នឹង។ កុំច្រលំ! មើលទៅពួកយើង ដូចជាលេងសើចបន្តិចមែន ប៉ុន្តែពួកយើងមានការប្តេជ្ញាចិត្ត និងពឹងលើសេចក្តីជំនឿ២៤ម៉ោងក្នុងមួយថ្ងៃ (ដកដង្ហើមសើចខ្លះ) បើមិនអ៊ីចឹងទេ យើងនឹងស្លាប់ (យើងនឹងវិលទៅរកការផឹកម្តងទៀត)។ ពួកយើងមានអារម្មណ៍ថា យើងមិនព្យាយាមស្វែងរកឋានសួគ៌នោះទេ ដោយសារតែឋានសួគ៌កំពុងស្ថិតនៅក្នុងចំណោពួកយើងឥឡូវនេះ គឺវាដូចជា ខ្ញុំនិងមិត្តភក្តិខ្ញុំ

អង្គុយជជែកគ្នាលេងតាមបែបសមញ្ញៗរាងរាល់ថ្ងៃ វាមានឥទ្ធិពលសំរាប់ពួកយើង ហើយឥទ្ធិពលនេះវានឹងកើនឡើង ហើយហូទៅដល់សង្គមដែរ ហើយនឹងនាំសន្តិភាពដល់មនុស្សគ្រប់គ្នា។